**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៣៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតមន្ទីរសារការី ខេមរា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីរដ្ឋប្បវេណី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមរដ្ឋប្បវេណី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១ .-**

ត្រូវបានបង្កើតមន្ទីរសារការីមួយ ដែលមានឈ្មោះថា **មន្ទីរសារការី ខេមរា** ( KHEMARA Notary Public) នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២ .-**

មន្ទីរសារការី ខេមរា មានទីស្នាក់ការនៅអាគារលេខ ១៤២ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។

**មាត្រា ៣ .-**

មន្ទីរសារការី ខេមរា មានតួនាទី និងភារកិច្ចដូចតទៅ ៖

- ទទួលធ្វើកិច្ចសន្យា ឬលិខិតគតិយុត្តទាំងឡាយដែលរូបវន្តបុគ្គល ឬនីតិបុគ្គលគ្រប់ប្រភេទត្រូវការ
- ផ្តល់ប្រឹក្សាយោបល់ចំពោះកិច្ចការពាណិជ្ជកម្ម វិនិយោគ កិច្ចការគ្រួសារ និងការគ្រប់គ្រងចាត់ចែងទ្រព្យសម្បត្តិ
- ផ្តល់ការបញ្ជាក់សុពលភាពចំពោះការបង្កើត ឬកែប្រែលក្ខន្តិកៈក្រុមហ៊ុន និងនីតិបុគ្គលគ្រប់ប្រភេទ
- ផ្តល់យថាភូតភាពដល់លិខិតគតិយុត្ត ឬកិច្ចសន្យា ឬឯកសារបកប្រែទាំងឡាយ តាមច្បាប់តម្រូវ ឬតាមការស្នើសុំរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលគ្រប់ប្រភេទ
- ស្នើសុំឱ្យស្ថាប័នអនុវត្តធ្វើការអនុវត្តដោយបង្ខំនូវលិខិតគតិយុត្ត ឬកិច្ចសន្យាដែលទទួលបានយថាភូតភាពពីសារការី
- ទទួលបញ្ជាក់ការចម្លងត្រឹមត្រូវតាមច្បាប់ដើមនូវរាល់លិខិតគតិយុត្ត ឬកិច្ចសន្យានានាតាមច្បាប់តម្រូវ ឬតាមការស្នើសុំរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលគ្រប់ប្រភេទ
- បញ្ជាក់ជានាហត្ថលេខា និងកាលបរិច្ឆេទនៃលិខិតគតិយុត្ត ឬកិច្ចសន្យានានា
- ធ្វើសំណើចុះបញ្ជី ឬចុះលេខាចារឹកទៅស្ថាប័នមានសមត្ថកិច្ច
- ទទួលតម្កល់ និងរក្សាទុកច្បាប់ដើមនៃកិច្ចសន្យា លិខិតឯកតោភាគីផ្សេងៗ មតកសាសន៍ និងលិខិតស្នាមគ្រប់ប្រភេទ
- ចេញច្បាប់ចម្លងនៃលិខិតយថាភូត និង
- ទទួលធ្វើកិច្ចការផ្សេងៗទៀតដែលអនុញ្ញាតដោយច្បាប់ និងបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា ៤ .-**

នៅពេលចាប់ផ្តើមប្រតិបត្តិការសកម្មភាព មន្ទីរសារការី ខេមរា ត្រូវតម្កល់ប្រាក់ចំនួន ៦០០.០០០.០០០ (ប្រាំមួយរយលាន) រៀល នៅធនាគារជាតិនៃកម្ពុជា សម្រាប់ការធានាទទួលខុសត្រូវក្នុងការបំពេញមុខងាររបស់ខ្លួន។

ក្នុងករណីដែលច្បាប់តម្រូវឱ្យមានការរំលាយ មន្ទីរសារការី ខេមរា ប្រាក់តម្កល់ខាងលើនេះត្រូវបង្វិលជូនស្ថាបនិក និងសហភាគា ដែលមានសិទ្ធិស្របច្បាប់ក្នុងការទទួលយក បន្ទាប់ពីបានកាត់កងទូទាត់បំណុល និងកាតព្វកិច្ចទាំងអស់ ដោយរាប់បញ្ចូលទាំងសោហ៊ុយនានាដែលចាំបាច់សម្រាប់ធានានិរន្តរភាពនៃការការពារផលប្រយោជន៍របស់អតិថិជនខ្លួន អនុលោមតាមបែបបទ និងនីតិវិធីជាធរមាន។

ដោយអនុលោមតាមច្បាប់ និងបទដ្ឋានគតិយុត្តជាធរមាននៃព្រះរាជាណាចក្រកម្ពុជា មន្ទីរសារការី ខេមរា អាចបង្កើតនូវយន្តការហិរញ្ញប្បទាន ឬយន្តការធានាផ្សេងទៀតដែលខ្លួនយល់ថាសមស្រប សម្រាប់បង្កើនទំនុកចិត្តរបស់ពលរដ្ឋ វិនិយោគិនជាតិ និងអន្តរជាតិ ចំពោះសេវារបស់ខ្លួន។

ទំនាក់ទំនងគតិយុត្តិរវាងស្ថាបនិក និងសហភាគា ត្រូវកំណត់ដោយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងដែលត្រូវអនុម័តដោយសារការីដែលទទួលបានការតែងតាំងតាមអនុក្រឹត្យនេះ។

**មាត្រា ៥ .-**

ត្រូវបានតែងតាំងជាសារការី នូវបុគ្គលដែលមានរាយនាមដូចខាងក្រោម ៖

១. **លោក ហួត ហាក់** ដើម្បីបំពេញមុខងារជាសហប្រធានមន្ទីរសារការី ខេមរា

២. **លោក ផូច សំគី** ដើម្បីបំពេញមុខងារជាសហប្រធានមន្ទីរសារការី ខេមរា

៣. **លោក សេង សត្យា** ដើម្បីបំពេញមុខងារជាសមាជិកមន្ទីរសារការី ខេមរា

ក្នុងករណីចាំបាច់ មន្ទីរសារការី ខេមរា អាចធ្វើការជ្រើសរើសសារការី ដែលទទួលបានការតែងតាំងពីរាជរដ្ឋាភិបាល ឬបុគ្គលិកផ្សេងទៀតសម្រាប់ជួយបំពេញតួនាទី និងភារកិច្ចរបស់ខ្លួនបាន។

**មាត្រា ៦ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ